Australian Embassy
Cambodia

The Asia Foundation

សេចក្តីប្រកាសព័ត៌មានរួម
រវាងអូស្ត្រាលី និងអង្គការមូលនិធិអាស៊ី
ស្តីពីការជំរុញអនាគតនៃវិស័យស្រាវជ្រាវកម្ពុជា

ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៦

ថ្ងៃនេះ អូស្ត្រាលី និងអង្គការមូលនិធិអាស៊ី បានរៀបចំវេទិកាគោលនយោបាយថ្នាក់ជាតិ ឆ្នាំ២០២៦ នៅរាជធានីភ្នំពេញ ដោយមានអ្នកចូលរួមជាង ១០០ នាក់ មកពីស្ថាប័នរាជរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ សាកលវិទ្យាល័យ សង្គមស៊ីវិល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងសហគមន៍ ដើម្បីពិភាក្សាអំពីរបៀបដែលកម្ពុជាអាចរក្សានិរន្តរភាពប្រព័ន្ធអេកូឡូស៊ីវិស័យស្រាវជ្រាវដ៏រឹងមាំ និងមានទំនាក់ទំនងផ្សារភ្ជាប់គ្នា ឆ្ពោះទៅឆ្នាំ ២០៣០។

ក្រោមប្រធានបទ «អនាគតនៃវិស័យស្រាវជ្រាវកម្ពុជា៖ និរន្តភាពទិន្នន័យ ធនធានមនុស្ស និងភាពជាដៃគូ រវាងវិស័យស្រាវជ្រាវ និងគោលនយោបាយ ឆ្ពោះទៅឆ្នាំ ២០៣០» វេទិកានេះបាន ផ្តោតលើរបៀបដែលកម្ពុជាអាចបន្តពង្រឹងការតាក់តែងគោលនយោបាយផ្អែកលើទិន្នន័យ ខណៈដែលទិដ្ឋភាពហិរញ្ញប្បទានពីម្ចាស់ជំនួយកំពុងមានការផ្លាស់ប្តូរ។

នៅក្នុងសុន្ទរកថាគន្លឹះ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មានប្រសាសន៍ថា វិស័យស្រាវជ្រាវកម្ពុជានឹងមានសារៈសំខាន់ សម្រាប់ដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍរបស់កម្ពុជា ហើយអនាគតរបស់វិស័យនេះនឹងពឹងផ្អែកលើការវិនិយោគលើធនធានមនុស្ស ជំនាញស្រាវជ្រាវ និងសមត្ថភាពស្ថាប័ន។

ឯកឧត្តម ដេរិក យីប ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍ថា « ការវិនិយោគរបស់ប្រទេសអូស្ត្រាលីលើវិស័យស្រាវជ្រាវកម្ពុជា គឺជាការវិនិយោគលើធនធានមនុស្ស ស្ថាប័ន និងភាពជាដៃគូ ដែលនឹងបន្តពង្រឹងដល់ការតាក់តែងគោលនយោបាយផ្អែកលើទិន្នន័យឱ្យមាននិរន្តរភាពលើសពីអាយុកាលនៃកម្មវិធីនីមួយៗ។"

លោកស្រី Meloney C. Lindberg តំណាងអង្គការមូលនិធិអាស៊ីប្រចាំកម្ពុជា មានប្រសាសន៍ថា « វិស័យស្រាវជ្រាវកម្ពុជាទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ហើយវេទិកានេះបង្ហាញពីអ្វីដែលអាចសម្រេចបាននៅពេលដែលរាជរដ្ឋាភិបាល អ្នកស្រាវជ្រាវ និងសហគមន៍ ធ្វើការរួមគ្នាដោយប្រើប្រាស់ទិន្នន័យដូចគ្នា។»

វេទិកានេះរួមមានការពិភាក្សាពេញអង្គស្តីពី ការភ្ជាប់តម្រូវការទិន្នន័យទៅនឹងការប្រើប្រាស់ទិន្នន័យ និងការផ្តល់ហិរញ្ញប្បទានដល់អនាគតនៃវិស័យស្រាវជ្រាវកម្ពុជា បន្ទាប់មកវគ្គពិភាក្សាតាមក្រុមអំពីវិស័យស្រាវ-ជ្រាវដែលអ្នកចូលរួមរិះរកមធ្យោបាយជាក់ស្តែងក្នុងការបោះជំហានទៅមុខ។ ការពិភាក្សាបានកំណត់អាទិភាពសម្រាប់របៀបវារៈវិស័យស្រាវជ្រាវកម្ពុជាឆ្ពោះទៅឆ្នាំ ២០៣០ និងជម្រើសយន្តការដើម្បីរក្សានិរន្តរភាពនៃកិច្ចសហការរវាងវិស័យស្រាវជ្រាវ និងរាជរដ្ឋាភិបាល។

វេទិកាគោលនយោបាយថ្នាក់ជាតិនេះ គឺជាគំនិតផ្តួចផ្តើមរបស់ កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា ដែលទទួលបានការគាំទ្រថវិកាពី រដ្ឋាភិបាលអូស្ត្រាលី និងអនុវត្តដោយអង្គការមូលនិធិអាស៊ី។ កម្មវិធីនេះពង្រឹងវិស័យស្រាវជ្រាវកម្ពុជា តាមរយៈការតភ្ជាប់គ្នារវាងអ្នកតាក់តែងគោលនយោបាយ អ្នកស្រាវជ្រាវ និងសហគមន៍។ កម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ នឹងត្រូវបញ្ចប់នៅពាក់កណ្តាលឆ្នាំ ២០២៧ ហើយកម្ពុជាកំពុងត្រៀមរៀបចំខ្លួនចាកចេញពីហានៈជាប្រទេសអភិវឌ្ឍន៍តិចតួច វេទិកាឆ្នាំនេះ គឺជាឱកាសដ៏មានតម្លៃមួយដើម្បីពិភាក្សាអំពីរបៀបដែលដៃគូកម្មវិធីអាចដាក់បញ្ចូលសមិទ្ធផលជោគជ័យ និងមុខងាររបស់ កម្មវិធីពន្លកចំណេះ ជាផ្នែកមួយនៃប្រព័ន្ធស្ថាប័នរបស់ខ្លួនព្រមទាំងពិភាក្សាអំពីសារៈសំខាន់នៃវិស័យស្រាវជ្រាវដ៏រឹងមាំ ក្នុងការផ្តល់មូលដ្ឋានដល់ការធ្វើសេចក្តីសម្រេចចិត្តរបស់អ្នកតាក់តែងគោល នយោបាយពាក់ព័ន្ធនឹងការអភិវឌ្ឍរយៈពេលវែងរបស់កម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

- ស្ថានទូតអូស្ត្រាលី៖ Media.Cambodia@dfat.gov.au
- កម្មវិធីពន្លកចំណេះ៖ ponlokchomnes@asiafoundation.org